00686810

E63/5

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 05 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

សំណុំរឿងលេខ:០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើបណ្តឹងរបស់អៀង ធីរិទ្ធ និង អៀង សារី ប្តឹងជំទាស់ចៅក្រម យូរ ឧត្តរា ចេញពីអង្គចៅក្រមពិសេស និងសំណើសុំឲ្យមានសវនាការជាសាធារណៈ

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង ធីរិទ្ធ
អៀង សារី
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS

ផាត់ ពៅសៀង
Diana ELLIS
ស សុវាន
Jaques VERGÈS
Philippe GRÉCIANO

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, Phnom Penh. Mail Po Box 71, Tel:+855(0)23 218914 Fax:023 218941 Web: www.eccc.gov.kh

## I. សេចក្ដីផ្ដើម

១. កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ គណៈកម្មាធិការរដ្ឋបាលតុលាការ (JAC) បានតែងតាំងចៅក្រមចំនួន ០៥ រូប ដើម្បីសម្រេចលើបណ្ដឹងចំនួន ០៣ ដែលប្ដឹងជំទាស់ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង ("អង្គចៅក្រមពិសេស")។ នៅថ្ងៃទី ០៩ និងនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ និងក្រុមមេធាវីការពារក្ដីរបស់ អៀង សារី បានដាក់បណ្ដឹងជំទាស់ ចៅក្រម យូរ ឧត្តរា ចេញពីអង្គចៅក្រមពិសេស ("បណ្ដឹងរបស់ អៀង ធីរិទ្ធ" និង "បណ្ដឹងរបស់ អៀង សារី")[១]។ នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ការិយាល័យសហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួនជំទាស់ទៅនឹងបណ្ដឹងរបស់ អៀង ធីរិទ្ធ[២]។ ចៅក្រម យូរ ឧត្តរា បានសម្រេចចិត្តមិនដកខ្លួនចេញពីអង្គចៅក្រមពិសេស ហើយនៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ អង្គចៅក្រមពិសេសបានចេញសេចក្ដីសម្រេចរួមលើបណ្ដឹងទាំងអស់ ដែលបានប្ដឹងជំទាស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង[៣]។ នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១១ ចៅក្រម យូរ ឧត្តរា បានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីចេតនារបស់ខ្លួនក្នុងការពុំឆ្លើយតបទៅនឹងបណ្ដឹងទាំងនេះ អនុលោមតាមវិធាន ៣៤(៧)[៤]។

២. វិធាន៣៤(៥)នៃវិធានផ្ទៃក្នុងចែងថាពាក្យបណ្ដឹងជំទាស់ត្រូវ "ដាក់ជូនទៅអង្គជំនុំជម្រះណាមួយដែលចៅក្រមនោះស្ថិតនៅ"។ កាលពីពេលមានការដាក់ពាក្យបណ្ដឹងទាំងនេះ ចៅក្រម យូរ ឧត្តរា ស្ថិតនៅក្នុងអង្គចៅក្រមពិសេស និងជាចៅក្រមបម្រុងនៃអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលា

---

[១] សំណើរបស់ អៀង ធីរិទ្ធ សុំជំទាស់ចៅក្រម យូរ ឧត្តរា ពីអង្គចៅក្រមពិសេសដោយសារការខ្វះឯករាជ្យភាព, ឯកសារលេខE63, ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១ ("សំណើរបស់ អៀង ធីរិទ្ធ")។ សំណើរបស់លោក អៀង សារី គាំទ្រសំណើរបស់លោកស្រី អៀង ធីរិទ្ធ ប្ដឹងជំទាស់ចៅក្រម យូរ ឧត្តរា ពីអង្គចៅក្រមពិសេសដោយសារការខ្វះឯករាជ្យភាព និងសំណើសុំឱ្យមានសវនាការសាធារណៈ ឯកសារ E63/1, ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១ ("សំណើរបស់លោក អៀង សារី")។

[២] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងរបស់ អៀង ធីរិទ្ធ ប្ដឹងជំទាស់ចៅក្រម យូរ ឧត្តរា ពីអង្គចៅក្រមពិសេស, ឯកសារលេខ E63/2, ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១។

[៣] សេចក្ដីសម្រេចលើបណ្ដឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្ដឹងជំទាស់ចំពោះចៅក្រម និល ណុន ចៅក្រម Silvia Cartwright, ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី, ឯកសារលេខ E55/4, ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១។

[៤] អនុស្សរណៈរបស់ចៅក្រម យូរ ឧត្តរា ជូនចំពោះលោកប្រធាន និងចៅក្រមអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងបណ្ដឹងជំទាស់រូបគាត់ពីអង្គចៅក្រមពិសេស, ឯកសារលេខ E63/4, ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១១។

ដំបូងបានបញ្ជូនពាក្យបណ្ដឹងរបស់ អៀង ធីរិទ្ធ ទៅកាន់គណៈកម្មាធិការរដ្ឋបាលតុលាការដើម្បីពិគ្រោះយោបល់។ បន្ទាប់មកគណៈកម្មាធិការរដ្ឋបាលតុលាការក៏បានបញ្ជូនបណ្ដឹងនេះត្រឡប់មកឱ្យអង្គជំនុំជម្រះសាលាដំបូងវិញ[៥]។ អង្គជំនុំជម្រះសាលាដំបូងមិនឯកភាពទៅនឹងការលើកឡើងរបស់មេធាវីការពារ អៀង សារី ដែលថាមានទំនាស់ផលប្រយោជន៍នៅក្នុងការសម្រេចរបស់អង្គជំនុំជម្រះលើបណ្ដឹងទាំងអស់នោះ[៦]។ អំណះអំណាងខាងលើរបស់មេធាវី អៀង សារី គឺសំអាងលើការចោទប្រកាន់ជារួមអំពីឯករាជ្យភាពរបស់តុលាការ និងពុំពាក់ព័ន្ធទៅនឹងចៅក្រមណាម្នាក់នៃអង្គជំនុំជម្រះសាលាដំបូងឡើយ។ អនុលោមតាមវិធាន ៣៤(៥) នៃវិធានផ្ទៃក្នុង និងសេចក្ដីសម្រេចរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើទាំងអស់នេះយ៉ាងត្រឹមត្រូវ។

៣. អនុលោមតាមវិធាន៣៤(៩) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចណាមួយដែលបានចេញនៅមុនពេលមានសេចក្ដីសម្រេចលើពាក្យបណ្ដឹងជិតចិត្តនោះ ត្រូវចាត់ទុកថាមានសុពលភាព។ ដោយហេតុថាអង្គចៅក្រមពិសេសបានបញ្ចប់នូវអាណត្តិរបស់ខ្លួនហើយនោះ បណ្ដឹងរបស់ អៀង ធីរិទ្ធ និង អៀង សារី គឺចាត់ទុកថាគ្មានមូលដ្ឋាន។ ទោះបីជាយ៉ាងដូច្នេះក្ដី ដោយយល់ឃើញពីសារៈសំខាន់នៃបញ្ហាដែលបានលើកឡើងនៅក្នុងបណ្ដឹងជិតចិត្តនោះ អង្គជំនុំជម្រះចេញនូវសេចក្ដីសម្រេចនេះដើម្បីសម្រេចទៅលើបញ្ហាសារធាតុនៃការចោទប្រកាន់នៅក្នុងពាក្យបណ្ដឹងដែលអង្គជំនុំជម្រះយល់ឃើញថា ត្រូវបានធ្វើឡើងដោយមិនសមហេតុផល។

## II. **សារធា**

៤. ការចោទប្រកាន់ចៅក្រម យូរ ឧត្តរា ថាមានភាពលម្អៀង កើតឡើងដោយសារគាត់មានតួនាទីនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូលកម្ពុជា ដែលបានតម្កល់សាលក្រមផ្ដន្ទាទោសលោកស្រី មូរ សុខហួរ ជាអ្នកនយោបាយមកពីគណបក្សប្រឆាំង ពីបទបរិហារកេរ្ដិ៍លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីខែ មិថុនា ឆ្នាំ ២០១០ កន្លងទៅ[៧]។ ដោយផ្អែកទៅលើ ការធ្វើសេចក្ដីអធិប្បាយរបស់តតិយជន

---

[៥] សេចក្ដីសម្រេចរបស់គណៈកម្មាធិការរដ្ឋបាលតុលាការទាក់ទងនឹងបណ្ដឹងជិតចិត្តប្រឆាំងនឹងចៅក្រម យូរ ឧត្តរា ពីអង្គចៅក្រមពិសេស, ឯកសារលេខ E63/3, ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១។

[៦] សំណើរបស់លោក អៀង សារី កថាខណ្ឌ ២។

[៧] *រឿងក្ដី អគ្គព្រះរាជអាជ្ញា តទល់នឹង មូរ សុខហួរ*, តុលាការកំពូល, សំណុំរឿងព្រហ្មទណ្ឌលេខ ២០១, ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩, សាលក្រមលេខ ៥៨, ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១០។

មកពីអង្គការមិនមែនរដ្ឋាភិបាលចំនួន ០៣ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងពីប្រេសិតពិសេសផ្នែកសិទ្ធិមនុស្សរបស់ អ.ស.ប នៅកម្ពុជា បណ្តឹងជិតចិត្តទាំងនេះលើកឡើងថា ការសម្រេចរបស់តុលាការលើករណីលោកស្រី មូរ សុខហួរ ពុំមានសំអាងហេតុគ្រប់គ្រាន់ ដែលខ្លួនចាត់ទុកទង្វើនេះថាជា "ការធ្វើតាមបញ្ជាលោកនាយករដ្ឋមន្ត្រី" ជាជាងការវិភាគឲ្យបានច្បាស់លាស់អំពីអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍[៨]។ ការដែលបណ្តឹងរបស់លោកស្រី មូរ សុខហួរ ប្តឹងលោកនាយករដ្ឋមន្ត្រីក្នុងពេលដំណាលគ្នាពីបទបរិហារកេរ្តិ៍ ត្រូវបានតុលាការបដិសេធចោលនោះ កាន់តែបង្ហាញឲ្យឃើញនូវភាពលម្អៀង[៩]។

៥. លើសពីនេះ ពាក្យបណ្តឹងទាំងនេះបានលើកឡើងថា រដ្ឋាភិបាលមាននូវ "ផលប្រយោជន៍ច្បាស់លាស់" នៅក្នុងការផ្តន្ទាទោសជនជាប់ចោទក្នុងសំណុំរឿងលេខ ០០២[១០]។ ផ្អែកតាមអ្វីដែលគេសន្មតថាជាឆន្ទៈរបស់ចៅក្រម យូរ ឧត្តរា ក្នុងការ "រៀបចំលទ្ធផល 'តាមការចង់បាន'" នៅក្នុងសំណុំរឿងលោកស្រី មូរ សុខហួរ នោះ គេអាចយល់ដោយមានហេតុផលត្រឹមត្រូវថា ក្នុងសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក នេះ លោកចៅក្រម យូរ ឧត្តរា ក៏ស្ថិតនៅក្រោមសម្ពាធរដ្ឋាភិបាលដូចក្នុងសំណុំរឿងក្តីលោកស្រី មូរ សុខហួរ ដែរ[១១]។

៦. បណ្តឹងជិតចិត្តរបស់ អៀង ធីរិទ្ធ បានទទួលស្គាល់ថា អង្គជំនុំជម្រះនៃ អ.វ.ត.ក ធ្លាប់បានបដិសេធពាក្យបណ្តឹងជិតចិត្តនានា ដែលបណ្តឹងទាំងនោះសំអាងទៅលើភាពពុំត្រឹមត្រូវដែលគេចោទថាមាននៅក្នុងសំណុំរឿងមុនៗ។ ទោះបីជាយ៉ាងដូច្នេះក្តី មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ នៅតែប្រកាន់ជំហរថា កាលៈទេសៈនាពេលបច្ចុប្បន្ន និងកាលពីពេលមុនមិនដូចគ្នាទេ ដោយហេតុថា ក្នុងសំណុំរឿងនេះមានទាំងភស្តុតាងជាក់លាក់អំពីទង្វើខុសឆ្គងកាលពីពេលមុនរបស់ចៅក្រម យូរ ឧត្តរា (I)[12] និងទំនាក់ទំនងរវាងទង្វើខុសឆ្គងនោះ និងកាលៈទេសៈនៃសំណុំរឿងបច្ចុប្បន្ន (II)[១៣]។

[៨] សំណើរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ២៦-២៧, ៣៨។

[៩] សំណើរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ២៦។

[១០] សំណើរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៤៤-៤៥។

[១១] សំណើរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៤៥។

[១២] សំណើរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៣៨។

[១៣] សំណើរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៤៣-៤៥។

៧. ដើម្បីគាំទ្រដល់សំណើសុំឱ្យមានសវនាការផ្ទាល់មាត់ បណ្តឹងដិតចិត្តរបស់ អៀង សារី បានលើកយកយុត្តិសាស្ត្រនៅតុលាការសហរដ្ឋអាមេរិកមកធ្វើជាសំអាង។ យុត្តិសាស្ត្រទាំងនោះក៏ធ្លាប់ត្រូវបានអង្គជំនុំជម្រះសាលាដំបូង លើកយកមកធ្វើជាសំអាងកាលពីពេលកន្លងមកដែរ[១៤]។ យុត្តិសាស្ត្រនោះបានកំណត់ថា ក្នុងករណីមានភាពលម្អៀងក្នុងសំណុំរឿងមួយ ភាគីអាចស្នើសុំឱ្យមានការស៊ើបអង្កេតបន្ថែមក្នុងសំណុំរឿងមួយទៀតពីភាពលម្អៀង[១៥]។ បណ្តឹងដិតចិត្តរបស់ អៀង សារី ក៏បានលើកឡើងដែរថា ដោយហេតុថា ប្រភពនៃការរិះគន់អំពីករណីរឿងក្តីលោកស្រី មូរ សុខហួរ កាន់តែលេចឡើងនោះ វាកាន់តែងាយជះឥទ្ធិពលទៅលើអ្នកសង្កេតការណ៍មិនលម្អៀង ថាទំនងជាមានភាពលម្អៀងនៅរឿងក្តីនោះមែន[១៦]។

## III. ការពិភាក្សាសម្រេច

៨. វិធាន៣៤(៤)(គ) នៃវិធានផ្ទៃក្នុងចែងថា បណ្តឹងដិតចិត្តប្រឆាំងនឹងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងត្រូវដាក់ "ពាក់ព័ន្ធទៅនឹងបញ្ហាមុនពេលជំនុំជម្រះ យ៉ាងយូរបំផុតត្រឹមពេលសវនាការបឋម"។ បន្ថែមពីលើនេះ វិធាន៣៤(៣) នៃវិធានផ្ទៃក្នុងតម្រូវឱ្យភាគីដាក់បណ្តឹងដិតចិត្តឱ្យឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលភាគីបានដឹងអំពីមូលហេតុនោះ។ បណ្តឹងទាំងនេះបានដាក់នៅក្នុងពេលមួយសមស្រប បន្ទាប់ពីចៅក្រម យូរ ឧត្តរា ត្រូវបានតែងតាំងជាចៅក្រមក្នុងអង្គចៅក្រមពិសេស។ ដូច្នេះ បណ្តឹងទាំងនេះត្រូវបានដាក់ទាន់ពេលវេលា[១៧]។

ក. <u>សំណើសុំឱ្យមានសវនាការជាសាធារណៈ:</u>

៩. ដូចដែលអង្គជំនុំជម្រះធ្លាប់បានសម្រេចកន្លងមក គឺថាទាំងក្នុងវិធានផ្ទៃក្នុង និងច្បាប់កម្ពុជា សវនាការជាសាធារណៈលើបណ្តឹងដិតចិត្តពុំមានភាពចាំបាច់ឡើយ។ អ.វ.ត.ក ឬតុលាការឧក្រិដ្ឋកម្មអន្តរជាតិក៏ពុំដែលធ្លាប់បានអនុវត្តទម្លាប់នេះម្តងណាដែរ។ តម្លាភាពត្រូវបានធានាគ្រប់គ្រាន់រួចស្រេចទៅហើយតាមរយៈការដាក់ចំណាត់ថ្នាក់ឯកសារពាក់ព័ន្ធថាជាឯកសារសាធារណៈនោះ[១៨]។

---

[១៤] សំណើរបស់ អៀង សារី កថាខណ្ឌ ៣៨។

[១៥] សំណើរបស់ អៀង សារី កថាខណ្ឌ ៣៨។

[១៦] សំណើរបស់ អៀង សារី កថាខណ្ឌ ៤១-៤២។

[១៧] សំណើរបស់ អៀង ធីរិទ្ធ កថាខណ្ឌ ៥។

[១៨] សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងដិតចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ, ឯកសារលេខ E5/3, ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ៣ ("សេចក្តីសម្រេចទាក់ទងនឹងចៅក្រម និល ណុន")។

១០. ការសំអាងរបស់ អៀង សារី ទៅលើសេចក្ដីសម្រេចរបស់តុលាការ សហរដ្ឋអាមេរិក ក្នុងសំណុំរឿង Bracy *តទល់នឹង* Gramley *និង* Cartalino *ទល់នឹង* Washington គឺមិនត្រឹមត្រូវនោះទេ[១៩]។ ក្នុងសំណុំរឿងទាំងនោះ តុលាការបានសម្រេចថា ក្នុងករណីមានភាពពុំត្រឹមត្រូវជាក់ស្ដែងក្នុងសំណុំរឿងមុន ត្រូវធ្វើការស៊ើបអង្កេតបន្ថែមដើម្បីសម្រេចថាតើចៅក្រមនោះមានភាពលម្អៀងដែរ ឬទេនៅក្នុងសំណុំរឿងបច្ចុប្បន្ន។ សំណុំរឿងនៅតុលាការសហរដ្ឋអាមេរិកនេះគឺពុំបានគាំទ្រដល់បណ្ដឹងរបស់ អៀង សារី ឡើយ។ ផ្ទុយទៅវិញ បណ្ដឹងជំទាស់របស់ អៀង សារី គឺបានស្នើសុំឱ្យមានការស៊ើប-អង្កេតទៅលើការចោទប្រកាន់ដែលថា ចៅក្រមមានភាពលម្អៀងនៅក្នុងសំណុំរឿងក្ដីកាលពីពេលមុន។

ខ. <u>ក្របខ័ណ្ឌគតិយុត្ត</u>

១១. យុត្តិសាស្ត្រនានារបស់ អ.វ.ត.ក បង្កើតបានជាក្របខ័ណ្ឌមួយសម្រាប់ការអនុវត្តវិធាន ៣៤ នៃវិធានផ្ទៃក្នុង:

១០. វិធាន ៣៤(២) នៃវិធានផ្ទៃក្នុងចែងថា "ភាគីអាចធ្វើបណ្ដឹងជំទាស់ចំពោះចៅក្រម ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធ ដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬបង្កើតឱ្យមានភាពលម្អៀង"។ អនុលោមតាមវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង បណ្ដឹងទាំងនេះ "ត្រូវបង្ហាញឱ្យច្បាស់លាស់អំពីមូលហេតុនៃបណ្ដឹង និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ"។

១១. លក្ខខណ្ឌតម្រូវនៃភាពអនាគតិត្រូវបានរំលោភ ក្នុងករណីដែលចៅក្រមមានភាពលម្អៀងពិតប្រាកដ ឬក្នុងករណីបង្កើតឱ្យមានភាពលម្អៀង។ ភាពលម្អៀងអាចនឹងកើតមាន កាលណា (ក) ចៅក្រមណាម្នាក់ជាភាគីមួយនៃរឿងក្ដី មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុចំពោះលទ្ធផលនៃរឿងក្ដី ឬប្រសិនបើការសម្រេចរបស់ចៅក្រមរូបនោះនឹងនាំឱ្យកើតចេញនូវបុព្វហេតុអ្វីមួយផ្សេងទៀតដែលចៅក្រមរូបនោះមានការពាក់ព័ន្ធ ឬ (ខ) កាលៈទេសៈទាំងនោះដែលធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងម្នាក់ដែលបានទទួលព័ត៌មានគ្រប់គ្រាន់យល់ឃើញដោយសមហេតុផលថាមានភាពលម្អៀង។

---

[១៩] សំណើរបស់ អៀង សារី កថាខណ្ឌ ៣៨ យោងរឿងក្ដី *Bracy តទល់នឹង Gramley*, 520 U.S. 899, 901 (1997) និង រឿងក្ដី *Cartalino តទល់នឹង Washington*, 122 F.3d 8, 9 (1997)។

១២. ក្នុងការវាយតម្លៃថាតើមានភាពលម្អៀង ឬគ្មាន អ្នកសង្កេតការណ៍មិនលម្អៀង ត្រូវតែជា "បុគ្គលដែលបានទទួលព័ត៌មានគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ដោយរួមបញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពអនាគតិ ហើយអ្នកសង្កេតការណ៍នោះយល់ថា អនាគតិគឺជាភារកិច្ចមួយក្នុងចំណោមភារកិច្ចនានា ដែលចៅក្រមត្រូវតែប្រកាន់ឱ្យបានខ្ជាប់ខ្ជួន"។ ចំណុចចាប់ផ្តើមនៃការកំណត់អំពីភាពលម្អៀងរបស់ចៅក្រម គឺការសន្មតជាមុនសិនអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រមដោយផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំងពួកគាត់ជាចៅក្រមនោះ។ ភាគីដែលប្តឹងជំទាស់មានបន្ទុកត្រូវបង្ហាញផ្ទុយពីការសន្មតទុកជាមុនបែបនេះដែលជាលក្ខខណ្ឌកម្រិតខ្ពស់តម្រូវឱ្យភាគីដាក់បណ្តឹងត្រូវបំពេញ[២០]។

គ. <u>អំពីខ្លឹមសារនៃបណ្តឹង</u>

១២. វិធាន៣៤ ពាក់ព័ន្ធនឹងភាពអនាគតិរបស់ចៅក្រមក្នុងរឿងក្តីមួយ។ ដើម្បីទទួលជោគជ័យ បណ្តឹងជំទាស់ត្រូវបង្ហាញពីអសមត្ថភាពរបស់ចៅក្រមដែលខ្លួនប្តឹងនោះ ក្នុងការដោះស្រាយទៅលើបញ្ហានានា ឬប្រព្រឹត្តមិនប្រកបដោយភាពអនាគតិចំពោះភាគី។ ភាពលម្អៀងដែលមាននៅក្នុងសំណុំរឿងផ្សេងរបស់ចៅក្រមដែលខ្លួនប្តឹងនោះពុំតម្រូវឱ្យមានការដកហូតសិទ្ធិរបស់ចៅក្រមរូបនោះឡើយ។ ការចោទប្រកាន់អំពីសម្បទាទូទៅរបស់បុគ្គលម្នាក់ក្នុងការបំពេញតួនាទីជាចៅក្រម ពុំស្ថិតក្នុងវិសាលភាពនៃវិធាន ៣៤ ឡើយ[២១]។

១៣. ដូចដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចកាលពីពេលកន្លងមក ឯករាជ្យភាពរបស់ចៅក្រមមានសារៈសំខាន់ក្រៃលែង។ ទោះបីជាយ៉ាងដូច្នេះក្តី ក្នុងបរិបទ អ.វ.ត.ក ឯករាជ្យភាពនេះត្រូវបានធានារួចហើយតាមរយៈយន្តការនានាដូចមានចែងក្នុងច្បាប់កម្ពុជា ដែលជាអ្នកធានាឯករាជ្យភាពរបស់អង្គចៅក្រម និងសម្បទារបស់បុគ្គលដែលត្រូវបំពេញតួនាទីជាចៅក្រម[២២]។ លើកលែងតែក្នុងករណីដែលការខ្វះឯករាជ្យភាពជះផលប៉ះពាល់ជាក់ស្តែង ដល់សំណុំរឿងណាមួយនៅចំពោះមុខ អ.វ.ត.ក តែប៉ុណ្ណោះ ទើបចំណុចនៃការខ្វះឯករាជ្យភាពនេះអាចបង្កើតបានជាមូលដ្ឋាននៃបណ្តឹង

---

[២០] សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះចៅក្រម និល ណុន, ចៅក្រម Silvia Cartwright, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ឯកសារលេខ E55/4, ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១, កថាខណ្ឌ១០-១២។

[២១] សេចក្តីសម្រេចទាក់ទងនឹងចៅក្រម និល ណុន កថាខណ្ឌ៧-៨។

[២២] សេចក្តីសម្រេចទាក់ទងនឹងចៅក្រម និល ណុន កថាខណ្ឌ៩-១៤។

ផិតចិត្ត អនុលោមតាមវិធាន៣៤[23]។ ស្រដៀងគ្នានេះដែរ តុលាការ ICTY ទាមទារឱ្យមានទំនាក់ទំនង រវាងការខ្វះឯករាជ្យភាពដែលបានចោទប្រកាន់ និងសំណុំរឿងដែលស្ថិតក្រោមការពិចារណា[២៤]។

១៤. ទោះបីបណ្តឹងទាំងពីរបង្កើតបានជាឯកសារមួយវែងអន្លាយ និងបានលើកយករបាយការណ៍របស់អ្នកសង្កេតការណ៍ដែលជាតតិយជនមកធ្វើជាសំអាងក្តី យោងតាមលក្ខខណ្ឌនៃបណ្តឹងសាទុក្ខ តួនាទីរបស់អង្គជំនុំជម្រះតុលាការកំពូលកំណត់ត្រឹមតែមូលដ្ឋានទាំងប៉ុន្មាន ដូចមានរៀបរាប់នៅក្នុងបណ្តឹងនោះតែប៉ុណ្ណោះ[25]។ ការចោទប្រកាន់ជាច្រើនអំពីភាពពុំត្រឹមត្រូវក្នុងបរិបទទូលំទូលាយនៃសំណុំរឿង រួមទាំងសេចក្តីសម្រេចពុំចាត់ការលើបណ្តឹងរបស់លោកស្រី មូរ សុខហួរ ប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រី និងការសម្រេចរបស់សភាជាតិក្នុងការដកអភ័យឯកសិទ្ធិតំណាងរាស្ត្ររបស់លោកស្រី មូរ សុខហួរ ពុំបង្កើតបានជាផ្នែកមួយនៃបណ្តឹងសាទុក្ខនៅចំពោះមុខតុលាការកំពូលរបស់កម្ពុជាឡើយ ហើយក៏ពុំអាចបង្កើតបានជាមូលដ្ឋាននៃការចោទប្រកាន់អំពីការខ្វះឯករាជ្យភាពដែរ។ លើសពីនេះ ការរិះគន់ភាគច្រើនគឺសំដៅទៅលើខ្លឹមសារនៃច្បាប់ស្តីពីការបរិហារកេរ្តិ៍ ដែលជាច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជា និងផលប៉ះពាល់របស់ច្បាប់នេះទៅលើសិទ្ធិបញ្ចេញមតិដោយសេរីនៅកម្ពុជា។ ចំណុចដែលបានលើកឡើងខាងលើគឺហួសពីវិសាលភាពនៃបណ្តឹងទាំងនេះ និងពុំស្ថិតក្រោមយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក ឡើយ។

១៥. របាយការណ៍នានាដែលពាក្យបណ្តឹងបានលើកយកមកធ្វើជាសំអាង រួមមានការលើកឡើងមួយចំនួនតូចអំពីកង្វះខាតរបស់តុលាការកំពូលក្នុងការផ្តល់សំអាងហេតុ[២៦] ហើយមានតែរបាយការណ៍មួយ

---

[២៣] សេចក្តីសម្រេចទាក់ទងនឹងចៅក្រម និល ណុន, កថាខណ្ឌ១១។

[២៤] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Delalic និងអ្នកផ្សេងទៀត*, សេចក្តីសម្រេចរបស់ការិយាល័យតុលាការ ICTY លើបណ្តឹងផិតចិត្តចៅក្រម អនុលោមតាមវិធាន ១៥ ឬទុកឱ្យចៅក្រមដកខ្លួនដោយខ្លួនឯង, ការិយាល័យតុលាការ ICTY (IT-96-21-T), ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៩, កថាខណ្ឌ ១០។

[២៥] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៤១៩។

[២៦] សហភាពអន្តរសភា, គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សរបស់សមាជិកសភា, សំណុំរឿងលេខ CMBD/47 - មូរ សុខហួរ -កម្ពុជា, សេចក្តីសម្រេចរបស់គណៈកម្មាធិការនៅឯកិច្ចប្រជុំពេញអង្គលើកទី ១៣០, ហ្សឺណែវ, ថ្ងៃទី ១២-១៥ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ២។ អង្គមហាសន្និបាត អ.ស.ប, ក្រុមប្រឹក្សាសិទ្ធិមនុស្ស, របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពនៅកម្ពុជា, Surya P. Subedi, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ អ.ស.ប. លេខ A/HRC/15/46, កថាខណ្ឌ ៤៣។

ប៉ុណ្ណោះដែលបានសម្ដែងកង្វល់ទៅលើឯករាជ្យភាពរបស់ចៅក្រម យូរ ឧត្តរា[២៧]។ អ្នកសង្កេតការណ៍មិនលម្អៀងនឹងមិនចាត់ទុកថា របាយការណ៍ទាំងនោះជាសេចក្ដីសម្រេចស្ដាពរលើឯករាជ្យភាពរបស់តុលាការកំពូលកម្ពុជា ឬរបស់សមាជិកម្នាក់ៗនៃតុលាការកំពូលឡើយ។ ដូចដែល អ.ប.ជ ធ្លាប់បានកត់សម្គាល់កន្លងមក ជាទូទៅមតិរបស់តតិយជនតែមួយមុខពុំទាន់គ្រប់គ្រាន់ឡើយក្នុងការនាំឱ្យគេយល់ដោយសមហេតុផលថា ចៅក្រម យូរ ឧត្តរា មានភាពលម្អៀង[២៨]។

១៦. លើសពីនេះ យើងពុំអាចដឹងឡើយអំពីទស្សនៈផ្ទាល់ខ្លួនរបស់ចៅក្រម យូរ ឧត្តរា ក្នុងនាមជាសមាជិកមួយរូបនៃអង្គចៅក្រមទាំង ០៥ រូប នៅពេលដែលសេចក្ដីសម្រេចធ្វើឡើងដោយសំឡេងភាគច្រើន។ កំណត់ហេតុនៃការប្រជុំពិភាក្សាសម្រេចជាឯកសារសម្ងាត់ ហើយការបោះឆ្នោតនៅឯតុលាការកំពូលកម្ពុជាក៏ធ្វើឡើងដោយសម្ងាត់ដែរ ចំណែកការសម្រេចវិញ គឺតុលាការទាំងមូលជាអ្នកធ្វើដោយពុំបញ្ជាក់ឱ្យដឹងអំពីគោលជំហររបស់សមាជិកក្រុមប្រឹក្សាជំនុំជម្រះណាម្នាក់ឡើយ។ លើសពីនេះ ច្បាប់ កម្ពុជាពុំមានចែងអំពីមតិជំទាស់របស់ចៅក្រមឡើយ[២៩]។ ដូច្នេះ យើងពុំអាចដឹងថាតើ ចៅក្រម យូរ ឧត្តរា មានជំហរយ៉ាងដូចម្ដេចឡើយ ចំពោះសាលដីការបស់តុលាការកំពូលនោះ។

---

[២៧] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, "ការវិភាគទៅលើភាពត្រឹមត្រូវនៃដំណើរការយុត្តិធម៌ ដែលនាំមកនូវការផ្ដន្ទាទោសលោកស្រី មូរ សុខហួរ អ្នកតំណាងរាស្ត្រដែលបានទទួលការជ្រើសតាំងតាមរយៈការបោះឆ្នោត", ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ២០។

[២៨] សេចក្ដីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឱ្យមានវិធានការសមរម្យពាក់ព័ន្ធនឹងសេចក្ដីថ្លែងការណ៍មួយចំនួនដែលធ្វើដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានតតាំងនឹងឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះ Katinka Lahuis និងចៅក្រម Rowan Downing, ០០២/២០-១០-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣), ឯកសារលេខ ៥, ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩, កថាខណ្ឌ ៨។

[២៩] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា២៤ (ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ) ចែងថា៖

១. ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវបានធ្វើជាសាធារណៈទេ។

២. ការពិភាក្សាត្រូវបានបើក និង ដឹកនាំដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

៣. ចៅក្រមម្នាក់ៗត្រូវបញ្ចេញមតិយោបល់របស់ខ្លួនក្នុងការពិភាក្សានេះ។

៤. ដំណើរការនៃការពិភាក្សា មតិយោបល់របស់ចៅក្រមម្នាក់ៗ និង ចំនួនសំឡេងនៃមតិត្រូវរក្សាទុកជាសម្ងាត់។

មាត្រា២៥ (ការសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះ) ចែងថា៖

១. ការសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើនរបស់ចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ។

២. ចៅក្រមម្នាក់ៗក្នុងក្រុមប្រឹក្សាជំនុំជម្រះនេះ ត្រូវមានសិទ្ធិសម្រេចស្មើគ្នា។

១៧. យោងតាមសំអាងហេតុខាងលើ នៅក្នុងកាលៈទេសៈនេះ អង្គជំនុំជម្រះពុំចាំបាច់សម្រេចថាតើខ្លួនគួរដកហូតសិទ្ធិចៅក្រមណាម្នាក់នៅ អ.វ.ត.ក ឡើយ ចំពោះការចោទប្រកាន់អំពីការខ្វះភាពឯករាជ្យនៅក្នុងសំណុំរឿងនៅចំពោះមុខតុលាការកំពូលកម្ពុជា និងដែលពុំពាក់ព័ន្ធនឹងសំណុំរឿងណាមួយនៅចំពោះមុខ អ.វ.ត.ក នោះ[៣០]។

**ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេច÷**

**បដិសេធ** សំណើសុំឲ្យមានសវនាការជាសាធារណៈ និង

**បដិសេធ** បណ្តឹងជិតចិត្តទាំងពីរ

អនុលោមតាមវិធាន ៣៤(៨) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១

ចៅក្រម និល ណុន

ចៅក្រម SILVIA CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម JEAN-MARC LAVERGNE

ចៅក្រម ធូ មណី

[៣០] *សូមមើល* សេចក្តីសម្រេចទាក់ទងនឹងចៅក្រម និល ណុន, កថាខណ្ឌ១១។